**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមហាផ្ទៃ**
**អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម**
លេខ:..........................................

# សេចក្តីជូនដំណឹង

ក្រសួងមហាផ្ទៃបានចេញសេចក្តីណែនាំលេខ០៣៥សណន ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៧ ស្តីពីការកែតម្រូវនិងការធ្វើមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋាន ដើម្បីជួយសម្រួលដល់ប្រជាពលរដ្ឋដែលកំពុងជួបប្រទះបញ្ហាខុសទិន្នន័យអត្តសញ្ញាណរបស់ខ្លួននៅក្នុងបញ្ជី និងសំបុត្រអត្រានុកូលដ្ឋាន ជាមួយឯកសារអត្តសញ្ញាណដទៃទៀត និងធ្វើឱ្យសាមីខ្លួនជួបការលំបាកយ៉ាងខ្លាំងក្នុងការស្នើសុំសេវារដ្ឋបាលផ្សេងៗ។

**អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ** សូមជូនដំណឹងដល់សាធារណជន ដែលមានបំណងស្នើសុំកែតម្រូវ ឬធ្វើមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋាន **សាមីខ្លួន ឬអាណាព្យាបាល ឬញាតិដែលរស់នៅក្នុងផ្ទះជាមួយ** អាចមកដាក់ពាក្យស្នើសុំកែតម្រូវ ឬមោឃភាពទិន្នន័យអត្រានុកូលដ្ឋានរបស់ខ្លួន នៅរៀងរាល់ម៉ោងធ្វើការ នៅទីតាំងដូចខាងក្រោម៖

១-នាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ ដែលមានអាសយដ្ឋាននៅផ្លូវជាតិលេខ១ សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ( ទល់មុខបុរីប៉េង ហួត បឹងស្នោរ )

២-សាលាក្រុង ស្រុក ខណ្ឌ នៃទីតាំងដែលបញ្ជីអត្រានុកូលដ្ឋានរបស់សាមីខ្លួនបាននឹងកំពុងរក្សាទុក។

បញ្ជាក់៖ រាល់ការស្នើសុំកែតម្រូវ ឬមោឃភាពសូមភ្ជាប់មកជាមួយនូវសំណុំឯកសារពាក់ព័ន្ធដែលជាកម្មវត្ថុនៃការស្នើសុំកែតម្រូវ ឬមោឃភាពនោះមកជាមួយផង។

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០១៧

លេខទំនាក់ទំនង៖
១-លោក ឌុច សុគន្ធ 017 444 344
២-លោក កែវ ផានិត 092 266 617